អង្គការខារ៉ាមកម្ពុជា

# តើធ្វើដូចម្តេច

# ដើម្បីសុវត្ថិភាពចំណាកស្រុក?

☞សូមមេត្តាទំនាក់ទំនងអង្គការខារ៉ាម តាមអាសយដ្ឋានៈ

- ✓ ផ្ទះលេខ ១៩៣ អាគារស៊ី ផ្លូវលេខ៦៣ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ក្រុងភ្នំពេញ។
- ✓ ទូរស័ព្ទលេខ: ០២៣ ២១៨ ០៦៩ / ០១២ ៩៦១៤២៣ / ០១២ ៩៤៩ ៩១៤
- ✓ អ៊ីម៉ែល caram.cam@online.com.kh
- ✓ វេបសាយ *www.caramcambodia.org*
- ✓ ហ្វេសប៊ុក *CARAM Cambodia*

*ដើម្បីធានាថាការធ្វើចំណាកស្រុកមានសុវត្ថិភាព និង ជួយកាត់បន្ថយការរំលោភបំពាន និងភាពងាយរងគ្រោះផ្សេងៗ នេះគឺជាព័ត៌មានចាំបាច់មួយចំនួនជុំវិញវដ្ត (ដំណាក់កាល)នៃការធ្វើចំណាកស្រុក ដែលអ្នកគួរស្វែងយល់ដូចតទៅ :*

**១. តើអ្នកគួរស្វែងយល់អ្វីខ្លះមុនពេលសំរេចចិត្តធ្វើចំណាកស្រុកស្វែងរកការងារធ្វើនៅក្រៅប្រទេស?**

ខាងក្រោមនេះ គឺជាព័ត៌មានមួយចំនួន ដែលអ្នកគួរស្វែងយល់មុនពេលសំរេចចិត្ត ធ្វើចំណាកស្រុក ស្វែងរកការងារធ្វើនៅក្រៅប្រទេស :

*១.១. លក្ខខណ្ឌការងារ (ដូចជា: ប្រភេទការងារ ជំនាញ កំរិតវប្បធម៌ កាយសម្បទា ។ល។)*

*១.២ កិច្ចសន្យាការងារ (ដូចជា: ភារកិច្ចដែលត្រូវធ្វើ ប្រាក់ឈ្នួល/ប្រៀវត្សន៍ រយៈពេល ពេលឈប់សំរាក បុណ្យជាតិ ប្រាក់បំណាច់ផ្សេងៗ ។ល។)*

*១.៣. ពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ និងអ្នកធ្លាប់ធ្វើចំណាកស្រុក (ដូចជា:ក្រុមគ្រួសារ អាជ្ញាធរមូលដ្ឋាន និងពលករដែលធ្លាប់ធ្វើចំណាកស្រុក ។ល។)*

*១.៤. ទំនៀមទំលាប់ ប្រពៃណី វប្បធម៌ និងភាសារបស់ប្រទេសទទួល*

*១.៥. គោលនយោបាយ និងច្បាប់របស់ប្រទេសបញ្ជូន និងប្រទេសទទួល ពលករទាក់ទិននឹងចំណាកស្រុកការងារ*

*១.៦. សិទ្ធិមនុស្ស និងសិទ្ធិពលករចំណាកស្រុក*

១.៧. ចំណាយផ្សេងៗ ទាក់ទិននឹងចំណាកស្រុកការងារ (ដូចជា: លិខិតឆ្លងដែន សៀវភៅបន្ទុក ប័ណ្ណអនុញ្ញាតិការងារ ការពិនិត្យសុខភាព ការស្នាក់នៅ ការហូបចុក ការបណ្តុះបណ្តាល ការដឹកជញ្ជូន ទឹកភ្លើង ពន្ធចំណូល បំណុល ។ល។)

១.៨. អាស័យដ្ឋានទីភ្នាក់ងារជ្រើសរើសពលករ និងនិយោជក

១.៩. ប្រវត្តិទីភ្នាក់ងារជ្រើសរើសពលករ និងនិយោជក

១.១០. អាស័យដ្ឋានកុងស៊ុល ឬស្ថានទូតកម្ពុជា ប្រចាំនៅប្រទេសទទួលពលករ

១.១១. អាស័យដ្ឋានស្ថាប័នរាជរដ្ឋាភិបាលកម្ពុជាដែលពាក់ព័ន្ធ និង អង្គការក្រៅរដ្ឋាភិបាលដែលធ្វើការលើវិស័យចំណាកស្រុក និងសិទ្ធិមនុស្សដែលអាចជួយធ្វើអន្តរាគមន៍បាន

១.១២ គុណសម្បត្តិ និងគុណវិបត្តិនៃការធ្វើចំណាកស្រុក ជាពិសេសចំណាកស្រុកដោយប្រថុយប្រថាន និងគ្មានឯកសារ (ខុសច្បាប់)

១.១៣. ព័ត៌មានចាំបាច់ផ្សេងៗ

## ២. តើអ្នកគួរស្វែងយល់អ្វីខ្លះ ពេលទៅដល់ប្រទេសទទួល?

នៅពេលអ្នកទៅដល់ប្រទេសទទួល អ្នកគួរស្វែងយល់ព័ត៌មានមួយចំនួន ទាក់ទិននឹង :

២.១. លក្ខខណ្ឌនៃការរស់នៅ

២.២ ទីតាំងកុងស៊ុល ឬស្ថានទូតកម្ពុជា ប្រចាំនៅប្រទេសទទួល

២.៣. ទីកន្លែងធ្វើការ និងទីកន្លែងរស់នៅរបស់អ្នក

២.៤. សេវាជំនួយផ្លូវច្បាប់ សេវាសុខភាព និងសេវាសង្គមផ្សេងៗ ក្នុងករណីមានបញ្ហា

២.៥. ស្ថានភាពសន្តិសុខ និងសុវត្ថិភាពនៃទីកន្លែងរស់នៅ

២.៦. កត់ត្រាចំណូល ចំណាយប្រចាំថ្ងៃ ខែ ឆ្នាំ

២.៧. ការគ្រប់គ្រងភាពតានតឹងក្នុងអារម្មណ៍

២.៨. ការគ្រប់គ្រងថវិកាផ្ទាល់ខ្លួន

២.៩. សេវាធនាគារ និងសេវាផ្ញើរប្រាក់

២.១០. ព័ត៌មានចាំបាច់ផ្សេងៗ

## ៣. តើអ្នកគួរស្វែងយល់អ្វីខ្លះពេលត្រឡប់មកប្រទេសកំណើត ឬ ពេលត្រូវសមាហរណកម្ម ត្រឡប់មកស្រុកកំណើតវិញ?

នៅពេលដែលអ្នកវិលត្រឡប់មកប្រទេសកំណើត ឬត្រូវសមាហរណកម្ម ត្រឡប់ មកស្រុកកំណើតវិញ អ្នកគួរតែស្វែងយល់ព័ត៌មានមួយចំនួនទាក់ទិននឹង :

៣.១. សេវាជំនួយផ្លូវច្បាប់ សេវាសុខភាព និងសេវាសង្គមផ្សេងៗ

៣.២ សេវាព័ត៌មានស្តីពីការងារ (ដូចជាទីភ្នាក់ងារមុខរបរជាតិ ។ល។)

៣.៣. ការបង្កើតមុខរបរ ឬអាជីវកម្មខ្នាតតូច

៣.៤. ទំនាក់ទំនងស្ថាប័នរាជរដ្ឋាភិបាលកម្ពុជាដែលពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាលនានា ដែលធ្វើការលើវិស័យចំណាកស្រុក និងសិទ្ធិមនុស្សដើម្បីស្វែងយល់ព័ត៌មាន ស្តីពីសេវាគាំទ្រ សេវាបញ្ជូន និងព័ត៌មានចាំបាច់ផ្សេងៗ ។



វេទិកាសាធារណៈស្តីពី សុវត្ថិភាពចំណាកស្រុក និងការជួញដូរមនុស្ស ក្នុងខេត្តកោះកុង